# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៨៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះកំណត់អំពីឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួករបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍សម្រាប់ប្រើប្រាស់បំពេញការងារចុះអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ សរសេរជាអក្សរកាត់ថា **ម.អ.ទ.**។

## ជំពូកទី២
## ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួក
### ផ្នែកទី១
### ឯកសណ្ឋាន

**មាត្រា២ ._**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវបានកំណត់ដូចខាងក្រោមៈ

ក- ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ខៀវទឹកប៊ិចចាស់ កឧប ថ្នេរឧប ប៉ូលស្មាសងខាង សម្រុងជើងអាវត្រង់ស្មើ ឆែកចំហៀងមានហោប៉ៅលើពីរ គម្របរាងស្លឹកពោធិ៍បិទដោយឡេវធម្មតា
- អាវដៃវែងពណ៌ខៀវទឹកប៊ិចចាស់កបើកថ្នេរឧប ប៉ូលស្មាសងខាង សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាល មានគម្របរាងចតុកោណកែងបិទដោយឡេវរូបព្រះសង្ការពណ៌មាស ឬប្រាក់ តាមឋានានុក្រម ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាល មានគម្របរាងចតុកោណកែងបិទដោយឡេវដូចហោប៉ៅខាងលើ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុងគឺអាវសឺមីពណ៌សដៃវែង ក្រវាត់កពណ៌ខៀវទឹកប៊ិចចាស់
- ខោជើងវែងពណ៌ខៀវទឹកប៊ិចចាស់ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរសងខាង មានហោប៉ៅចំនួនបី ហោប៉ៅខាងក្រោយមួយដេរបង្កប់ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ មានកែង កខ្លី ចងខ្សែនិងស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រមទំហំក្បាលខ្សែក្រវ៉ាត់មានទទឹង៣៥ម.ម. បណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅចំកណ្តាល។

ខ- ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី មានពណ៌ខៀវទឹកប៊ិចចាស់

- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខៀវទឹកប៊ិចចាស់ ឬសំពត់ហ្សីបពណ៌ខៀវទឹកប៊ិចចាស់ សម្រុងក្រោមជង្គង់ ចែកក្រោយ រូតពីក្រោយ
- ស្បែកជើងពណ៌ខ្មៅឃ្លុបមុខឃ្លុបក្រោយ មានកែងនិងស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រមទំហំក្បាលខ្សែក្រវ៉ាត់មានទទឹង៣៥ម.ម. បណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅចំកណ្តាល
- ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១។

## ជំពូកទី២
## សញ្ញាសម្គាល់

**មាត្រា៣ .-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសញ្ញាសម្គាល់ដែលត្រូវពាក់នៅលើដៃអាវខាងស្តាំ។ សញ្ញាសម្គាល់នេះធ្វើអំពីក្រណាត់ក្រាស់ពណ៌ផ្ទៃមេឃរាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម. មានរូបផែនដី រំលេចដោយអក្សរ "**ម.អ.ទ**"និងរូបនិមិត្តសញ្ញាប្រេកង់សំវិទ្យុនៅចំកណ្តាល ព័ទ្ធជុំវិញដោយពាក់កណ្តាលខាងលើជាអក្សរខ្មែរ "មន្ត្រីអធិការកិច្ចទូរគមនាគមន៍" និងពាក់កណ្តាលខាងក្រោមជាអក្សរអង់គ្លេស"Inspector of Telecoms" ខណ្ឌដោយសញ្ញាផ្កាយចំនួនពីរ។ សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី២។

**មាត្រា៤ .-**

សញ្ញាសម្គាល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាសញ្ញាធ្វើពីលោហធាតុ រាងសំប៉ែត ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ព្យួរលើហោប៉ៅអាវខាងស្តាំ ទំហំរង្វង់អង្កត់ផ្ចិត៦០ម.ម.។ សញ្ញាសម្គាល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ព្យួរលើហោប៉ៅរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៣។

**មាត្រា៥ .-**

សញ្ញាសម្គាល់សម្រាប់ពាក់ជាប់ចុងកអាវ ធ្វើពីលោហធាតុរាងសំប៉ែតពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រមជាសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទំហំ១៥ម.ម.។ សញ្ញាសម្គាល់សម្រាប់ពាក់ជាប់ចុងកអាវរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៤។

**មាត្រា៦ .-**

ស្លាកសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ចទូរគមនាគមន៍ សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមាន បណ្តោយប្រវែង៨,៥ស.ម. ទទឹង២,៥ស.ម. សរសេរអក្សរពណ៌ទឹកមាស ឬទឹកប្រាក់តាមឋានានុក្រមមានផ្ទៃពណ៌ខៀវចាស់ មានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមុខងារមន្ត្រីរាជការជាអក្សរខ្មែរពីក្រោម។ ស្លាកសម្គាល់ឈ្មោះរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៥។

## ផ្នែកទី៣
## សញ្ញាសក្តិ

**មាត្រា៧ _**

សញ្ញាសក្តិស្មា មានបាតក្រោមប្រវែង៦(ប្រាំមួយ)សង់ទីម៉ែត្រ បណ្តោយពីលើបាតក្រោមប្រវែង១៣(ដប់បី)សង់ទីម៉ែត្រ និងមានទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧(បួនក្បៀសប្រាំពីរ)សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា មាន៧(ប្រាំពីរ)ថ្នាក់ តាមមុខតំណែងរបស់មន្ត្រីរាជការដូចខាងក្រោម៖

១- **ថ្នាក់អគ្គាធិការនិងអគ្គនាយក**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ធ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុហើយនៅចន្លោះអក្សរ "**ម.អ.ធ.**" និងរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនបួន។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៦។

២- **ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ធ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ ហើយនៅចន្លោះអក្សរ "**ម.អ.ធ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនបី។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៧។

៣-**ថ្នាក់អធិការនិងប្រធាននាយកដ្ឋាន**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ មានអក្សរ"**ម.អ.ធ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសនៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ ហើយនៅចន្លោះមានអក្សរ "**ម.អ.ធ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនពីរ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៨។

៤- **ថ្នាក់អធិការរង អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរប.ទ រាជធានី ខេត្ត**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ មានអក្សរ"**ម.អ.ធ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ ហើយនៅចន្លោះអក្សរ"**ម.អ.ធ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនមួយ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៩។

៥- **ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរប.ទ រាជធានី ខេត្ត**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ធ.**"ពណ៌ប្រាក់នៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ ហើយនៅចន្លោះអក្សរ "**ម.អ.ធ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សីវិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍...

និងទូរគមនាគមន៍រាងផ្កាយពណ៌ប្រាក់ចំនួនបី។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១០។

៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យប.ទ រាជធានី ខេត្តៈ មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ឆ.**"ពណ៌ប្រាក់នៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិទ្បុ ហើយនៅចន្លោះអក្សរ"**ម.អ.ឆ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិទ្បុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌ប្រាក់ចំនួនពីរ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១១។

៧- ថ្នាក់មន្ត្រីៈ មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ឆ.**" ពណ៌ប្រាក់នៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិទ្បុ ហើយនៅចន្លោះអក្សរ "**ម.អ.ឆ.**" និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិទ្បុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌ប្រាក់ចំនួនមួយ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១២។

## ផ្នែកទី៤
## មួក

**មាត្រា៨ .-**

មួកកាស្កែត មាន៥(ប្រាំ)ថ្នាក់៖

១ -**ថ្នាក់អគ្គាធិការនិងអគ្គនាយកៈ** មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្នាក់វិញខ្នាតធំពណ៌មាសពីលើជើងមួកពណ៌ខ្មៅព្រមទាំងនៅខាងចុងខ្សែធ្នាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស ខាងក្រោមខ្សែធ្នាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ជាខ្សែរសយពណ៌មាសដោយម៉ាស៊ីនកុំព្យូទ័រ ទម្រង់ស្លែងក្របីធំពេញក្បាំង ៥សន្លឹក ដល់ជើងមួក។

២- **ថ្នាក់អគ្គាធិការរងនិងអគ្គនាយករងៈ** មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្នាក់វិញខ្នាតតូចពណ៌មាសពីលើជើងមួកពណ៌ខ្មៅព្រមទាំងនៅខាងចុងខ្សែធ្នាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស ខាងក្រោមខ្សែធ្នាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេស ប៉ាក់ជាខ្សែរសយពណ៌មាសដោយម៉ាស៊ីនកុំព្យូទ័រ ទម្រង់ស្លែងក្របីធំពេញក្បាំង ៥សន្លឹក ដល់ជើងមួក។

៣- **ថ្នាក់អធិការ ប្រធាននាយកដ្ឋាន អធិការរង អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរប.ទ រាជធានី ខេត្តៈ** មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្នាក់វិញខ្នាតតូចពណ៌មាសពី

ពីលើជើងមួកពណ៌ខ្មៅ ព្រមទាំងនៅខាងចុងខ្សែធ្លាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស ខាងក្រោមខ្សែធ្លាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ជាខ្សែសយពណ៌មាស ដោយម៉ាស៊ីនកុំព្យូទ័រ ទម្រង់ស្នែងក្របីធំពាក់កណ្តាលក្បាំង ៣សន្លឹក។

**៤- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមន្ទីរប.ទ រាជធានី ខេត្ត អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យប.ទ រាជធានី ខេត្ត:** មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានខ្សែធ្លាក់វិញខ្នាតតូចពណ៌ប្រាក់ពីលើជើងមួកពណ៌ខ្មៅ ព្រមទាំងនៅខាងចុងខ្សែធ្លាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌ប្រាក់ ខាងក្រោមខ្សែធ្លាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ជាខ្សែសយពណ៌ប្រាក់ដោយម៉ាស៊ីនកុំព្យូទ័រទម្រង់ស្នែងក្របីធំពាក់កណ្តាលក្បាំង ៣សន្លឹក។

**៥- ថ្នាក់មន្ត្រី:** មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្លាក់វិញខ្នាតតូចពណ៌ប្រាក់ពីលើជើងមួកពណ៌ខ្មៅ ព្រមទាំងនៅខាងចុងខ្សែធ្លាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌ប្រាក់ ខាងក្រោមខ្សែធ្លាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើចុងក្បាំងមានដេរភ្ជាប់ខ្សែធ្លាក់វិញពណ៌ប្រាក់ទំហំ៥ម.ម.។

មួកទាំងប្រាំថ្នាក់ខាងលើរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១៣។

**មាត្រា៩ _**

ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួក ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗចំនួន២(ពីរ)សម្រាប់ នូវឯកសណ្ឋាន សម្រាប់ប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា១០ _**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ មួក និងត្រូវមានលិខិតបញ្ជាបេសកកម្ម នៅពេលប្រតិបត្តិការអនុវត្តច្បាប់។ ក្នុងពិធីប្រជុំឬពិធីការផ្សេងៗទៀត បើចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួក ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**ជំពូកទី៣**

**ទោសប្បញ្ញត្តិ**

**មាត្រា១១ _**

ជនណាក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់ និងមួក របស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ១៧៤ អនក្រ.បក........ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**



ឯកសណ្ឋានអាវដៃវែង ឯកសណ្ឋានអាវដៃខ្លី

**ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**






**ឧបសម្ព័ន្ធទី៣**

**នៃអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសម្គាល់សម្រាប់ព្យួរលើហោប៉ៅអាវរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**



**ឧបសម្ព័ន្ធទី៤**

**នៃអនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសម្រាប់ពាក់ជាប់ចុងកអាវរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**




សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវពណ៌មាស




សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវពណ៌ប្រាក់

**ឧបសម្ព័ន្ធទី៥**

**នៃអនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូស្លាកសម្គាល់ឈ្មោះរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**




ស្លាកសម្គាល់ឈ្មោះពណ៌មាស




ស្លាកសម្គាល់ឈ្មោះពណ៌ប្រាក់

រាក់

v

**ឧបសម្ព័ន្ធទី៦**

**នៃអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អគ្គាធិការនិងអគ្គនាយក**



## ឧបសម្ព័ន្ធទី៧

## នៃអនុក្រឹត្យលេខ.១៧៦.អនក្រ.បក..... ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦

## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍

### គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង



**ឧបសម្ព័ន្ធទី៨**

**នៃអនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អធិការនិងប្រធាននាយកដ្ឋាន**



**ឧបសម្ព័ន្ធទី៩**

**នៃអនុក្រឹត្យលេខ១៨៧ អនក្រ.បក...... ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អធិការរង អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរប.ទ**

**រាជធានី/ខេត្ត**



**ឧបសម្ព័ន្ធទី១០**

**នៃអនុក្រឹត្យលេខ ១៧៦ អនក.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល**

**និងអនុប្រធានមន្ទីរប.ទ រាជធានី/ខេត្ត**



**ឧបសម្ព័ន្ធទី១១**

**នៃអនុក្រឹត្យលេខ១៧៦.អនក្រ.បក...... ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យប.ទ រាជធានី/ខេត្ត**



**ឧបសម្ព័ន្ធទី១២**

**នៃអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់មន្ត្រី**



## ឧបសម្ព័ន្ធទី១៣

### នៃអនុក្រឹត្យលេខ ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦

### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍

### គំរូមួកភាស្កេត

| | |
|---|---|
|  | ថ្នាក់អគ្គាធិការនិងអគ្គនាយក |
|  | ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង |
|  | ថ្នាក់អធិការ ប្រធាននាយកដ្ឋាន អធិការរង អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរប.ទ រាជធានី/ខេត្ត |
|  | ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមន្ទីរប.ទ រាជធានី/ខេត្ត អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យប.ទ រាជធានី/ខេត្ត |
|  | ថ្នាក់មន្ត្រី |